ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តុលាការប្រជាធិបតេយ្យខ្មែរ
## សាលាដំបូងខេត្តស្វាយរៀង

សាលាដំបូងខេត្តស្វាយរៀង
សំណុំរឿងព្រហ្មទណ្ឌលេខ:៦៨
ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ:២២៦ (ខ)
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តស្វាយរៀង កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២២ខែកញ្ញាឆ្នាំ២០២២ ដែលមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted]ានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តស្វាយរៀង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តស្វាយរៀង

**មេធាវីការពារសិទ្ធិ**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

**ដើម្បីជំនុំជំរះ:** លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៦៨ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ជា ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ[redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] រី (ស្លាប់) ម្តាយឈ្មោះ [redacted]ធីម (រស់) ប្រពន្ធឈ្មោះ ព្រាប សាលឹម មានកូនចំនួន ០១ នាក់ ទោសពីមុនគ្មាន។**(ឃុំខ្លួននៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២)**

២.ឈ្មោះ [redacted]សារឿន ហៅ គ ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូ[redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] ផន (រស់) ម្តាយឈ្មោះ [redacted]ជា(រស់) ប្រពន្ធឈ្មោះ [redacted] សាម៉ៃ មានកូនចំនួន ០៤ នាក់ ទោសពីមុនគ្មាន។**(ឃុំខ្លួននៅថ្ងៃទី១១ ខែមីនាឆ្នាំ២០២២)**

៣.ឈ្មោះ [redacted]ស៊ាន ហៅ គោយ ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតស្ថិតនៅភូមិ[redacted] ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិធ្លល់ សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] សែម (រស់) ម្តាយឈ្មោះ [redacted]ណោន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] អឿន មានកូនចំនួន ០៤ នាក់ ទោសពីមុនគ្មាន។**(ឃុំខ្លួននៅថ្ងៃទី១១ ខែមីនាឆ្នាំ២០២២)**

ពីបទ: *រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងទៅនឹងជនល្មើស* ប្រព្រឹត្តនៅភូមិអង្គាសដី ឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៤០ កថាខណ្ឌទី១ ចំណុចទី៥ នៃក្រមព្រហ្មទណ្ឌ។

**<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>**

ឈ្មោះ [redacted]សីម៉ា ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទី កន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន



Scanned with CamScanner

ស្ថិតនៅភូមិអង្គាសដី ឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] រ៉ន (ស្លាប់) ម្តាយឈ្មោះ [redacted] ចំពូ (រស់) ប្តីឈ្មោះ [redacted] វៃ (លែងលះគ្នា) មានកូនចំនួន ០១ នាក់។

## **ការប្រព្រឹត្តរបស់ជនជាប់ចោទ:**

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ នៅចំណុចភូមិអង្គាសដី ឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង មានករណី **រំលោភសេពសន្ថវ:មានស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស** មួយបង្កឡើងដោយជនសង្ស័យចំនួន០៣នាក់ ១.ឈ្មោះ [redacted] ជា ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ២.ឈ្មោះ [redacted] សាមឿន ហៅ គ ភេទប្រុស អាយុ៤៦ឆ្នាំ ជនជាតិខ្មែរ ៣.ឈ្មោះ [redacted] ស៊ាន ហៅ គោយ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ បានរួមគ្នាធ្វើសកម្មភាពចាប់រំលោភជនរងគ្រោះឈ្មោះ [redacted] សីម៉ា ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ បានសម្រេច ក្រោយពេលកើតហេតុជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានចុះដល់កន្លែងកើតហេតុធ្វើការស្រាវជ្រាវ រហូតដល់ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ទើបធ្វើការឃាត់ខ្លួនជនសង្ស័យទាំង ៣ នាក់ ខាងលើមកធ្វើការសាកសួរ រួចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមនីតិវិធីតែម្តង។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៦៨ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តស្វាយរៀង។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ: ៤៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តស្វាយរៀង។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ:១១៩ **អ.យ.គ /២២** ចុះថ្ងៃទី២៦ខែឧសភាឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តស្វាយរៀង។

-បានឃើញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជំរះលេខ: ៨៤៩ តក.ព្រទ/២២ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្វាយរៀង។

-បានឃើញ សំណុំរឿងជំនុំជំរះលេខ: **១២១** ចុះថ្ងៃទី១៣ខែមិថុនាឆ្នាំ២០២២របស់សាលាដំបូងខេត្តស្វាយរៀង។

-បានឃើញដីកាសម្រេចចាត់តាំងចៅក្រមជំនុំជំរះលេខ: **១២៩ ជ.ស.រ/២២** ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តស្វាយរៀង។

## **ពេលសវនាការ**

ឈ្មោះ [redacted] ជា ជាជនជាប់ចោទ បានឆ្លើយថា ខ្លួនពុំបានចូលរួមប្រព្រឹត្តបទល្មើសរំលោភនារីឈ្មោះ [redacted] សីម៉ា កាលពីម៉ោង៨ យប់ នាថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ នោះទេ តែខ្លួនបានចូលផឹកស៊ីជាមួយឈ្មោះ [redacted] សីម៉ា នៅផ្ទះឈ្មោះ [redacted] សាមឿន ហៅ គ ចាប់ពីម៉ោង៦ ល្ងាច ដល់ម៉ោង ៨ យប់ ឈ្មោះ [redacted] សីម៉ា និងអ្នកផ្សេងទៀតចេញទៅផ្ទះរៀងខ្លួនឯងខ្លួននៅបង្អើយស្រាជាមួយឈ្មោះ មឿន រួចចេញទៅផ្ទះម្នាក់ឯង។ លុះព្រឹកឡើងឮថាខ្លួនចាប់រំលោភគេទៅវិញ។ សំណូមពរតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។

ឈ្មោះ [redacted] សាមឿន ជាជនចាប់ចោទ បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចបទចោទប្រកាន់នោះទេ តែល្ងាចនោះនៅផ្ទះខ្លួនមានហូបចុក រួមទាំងមានឈ្មោះ [redacted] សីម៉ា ផងដែរ ដល់ម៉ោង៧យប់ ឈ្មោះ [redacted] ស៊ាន ឱ្យទៅផ្ទះមុនប្រហែល ៥ នាទី ឈ្មោះ [redacted] សីម៉ា ទៅតាមក្រោយឯខ្លួន និងបង សេក ជា នៅបង្អើយស្រា ទល់តែបង [redacted] ជា ទៅផ្ទះឯខ្លួនក៏ទៅដេក ដល់ព្រឹកថា ដោយមានឈ្មោះ [redacted] ជា ឈ្មោះ [redacted] សាមឿន ជាអ្នកជួយចាប់ដៃជើង រំលោភ ឈ្មោះ [redacted] សីម៉ា ទៅវិញ។ សំណូមពរតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។

ឈ្មោះ [redacted] ស៊ាន ជាជនជាប់ចោទ បានឆ្លើយថា ខ្លួនពុំបានប្រព្រឹត្តដូចបទចោទប្រកាន់ ប៉ុន្តែកាលពីល្ងាចថ្ងៃនោះបានផឹកស៊ីនៅផ្ទះឈ្មោះ សាមឿន ជាមួយឈ្មោះ សំ សីម៉ា ពិតមែន។ ដល់ម៉ោង ៨ យប់ ខ្លួនចេញទៅផ្ទះដោយជិះកង់ ចំណែកឈ្មោះ [redacted] សីម៉ា ម្ចាស់ផ្ទះ ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ជា នៅហូបបន្ត ដល់ព្រឹកឮថា ពួកខ្លួនចាប់រំលោភឈ្មោះ [redacted] សីម៉ា ទៅវិញ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ខ្លួនត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ សំណូមពរតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។

ឈ្មោះ [redacted] សីម៉ា ជាដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយថា ខ្លួននៅតែប្តឹងឈ្មោះ [redacted] ស៊ាន ហៅ គោយ ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ជា ដែលអ្នកទាំងបីនាក់នេះបានចាប់រំលោភសេពសន្ថវៈលើខ្លួន កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល៨យប់ ដោយកាលពីល្ងាចថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ ខ្លួនមកពីធ្វើក្រចកឱ្យអ្នកភូមិ ជិះកង់ជិតដល់ផ្ទះរបស់ឈ្មោះ [redacted] សាមឿន ហៅ គ ស្រាប់តែឈ្មោះ [redacted] ស៊ាន ហៅ គោយ ឃាត់ឱ្យខ្លួនចូលផឹកជាមួយពួកគាត់សិន។ ពេលខ្លួនចូលទៅផឹកមានគ្នាចំនួន០៣នាក់ គឺម្ចាស់ផ្ទះឈ្មោះចាន់ សាមឿន , ឈ្មោះ គោយ និងឈ្មោះ [redacted] ជា ឯម្ចាស់ផ្ទះស្រីនៅភ្នំពេញ។ ពេលខ្លួនផឹកបានបន្តិចខ្លួនទៅផ្ទះវិញ តែឈ្មោះ គោយ ចាប់ឃាត់ឱ្យនៅផឹកទៀត រហូតខ្លួនស្រវឹង ខ្លួនក៏បរកង់ចេញ ក៏ចាប់យកកង់ខ្លួនលាក់បាត់ ខ្លួនសួររកត្រូវឈ្មោះ គោយ ចាប់អោបថើបនៅក្នុងភូមិផ្ទះ សាមឿន ខ្លួនរើបម្រាស់ក៏ឈ្មោះ សាមឿន និងឈ្មោះ ជា មកជួយចាប់ខ្លួនរើលែងបាន ត្រូវឈ្មោះ គោយ រំលោភខ្លួនដោយមានឈ្មោះ [redacted] ជា ឈ្មោះ [redacted] សាមឿន ជាអ្នកជួយចាប់ដៃជើង និងមានម្រាមដៃរុកចូលច្រមុះខ្លួនទាំងពីរបណ្តាលឱ្យខ្លួនសន្លប់លែងដឹងខ្លួន គឺច្បាស់ជាឈ្មោះ សាមឿន និងឈ្មោះ ជា រំលោភខ្លួនដែរ។ ពេលខ្លួនដឹងខ្លួន ដើរទៅផ្ទះដេកសន្លប់ទៀតរហូតទាល់ភ្លឺទើបដឹងខ្លួន ខ្លួនប្រាណប្រឡាក់ដី ពេលនោះខ្លួនជិះកង់ដែលខ្លួនទៅយកស្បែកជើង តែពុំឃើញស្រាប់តែបងស្រីឈ្មោះ [redacted] ថាវី ប្រាប់ខ្លួនថាគាត់ឃើញអ្នកទាំងបីចាប់រំលោភខ្លួន និងសួរថារឿងណឹងមិចហើយ ខ្លួនក៏ទៅប្រាប់បងស្រីឈ្មោះ [redacted] ណារី ថាអ្នកទាំងបីនាក់ ចាប់រំលោភខ្លួន កាលពីយប់មិញ ខ្លួនទៅប្តឹងប្រធានភូមិ រហូតសមត្ថកិច្ចហៅ ខ្លួនទៅចង្អុលមុខ។ ក្នុងរឿងនេះខ្លួនប្តឹងសុំទាមទារជំងឺចិត្តចំនួន ១៥ ០០០ ដុល្លារអាមេរិក។

ឈ្មោះ [redacted] ចំពូ ជាសាក្សី បានឆ្លើយថា រឿងហេតុកូនស្រីខ្លួនឈ្មោះ [redacted] សីម៉ា ត្រូវគេចាប់រំលោភកាលពីយប់ថ្ងៃទី០៥ ខែមីនាឆ្នាំ២០២២ គឺខ្លួនពុំបានឃើញផ្ទាល់ភ្នែកទេ ដោយពេលមុនកើតហេតុកូនខ្លួនជាស្រីមេម៉ាយ រស់នៅជាមួយខ្លួន និងកូនវាម្នាក់ដែរ ហើយចេះធ្វើក្រចកដៃជើង ឱ្យគេនៅថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃសម្រាករបស់កម្មករ គឺទៅធ្វើល្ងាចទើបជិះកង់មកវិញ តែថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ ខ្លួនពុំឃើញកូនស្រីខ្លួនត្រឡប់មកផ្ទះវិញ ខ្លួនក៏អង្គុយចាំរហូតដល់ម៉ោង ៨ យប់ ទើបឃើញបរកង់មក ខ្លួនសុទ្ធតែដី ខ្លួនសួរ វាពុំមាត់ចេះតែយប់ និងទៅដេកថ្ងូរ ខ្លួនមិនស្រួលខ្លួនក៏ទៅដេកដែរ។ រហូតព្រឹកឡើងទើបវា ប្រាប់ខ្លួន និងបងស្រីវាថា យប់មិញឈ្មោះ គោយ ឈ្មោះ គ និងឈ្មោះ ជា ចាប់រំលោភវា ហើយវា និងបងវា ទៅប្តឹងសមត្ថកិច្ចរហូតចាប់បានអ្នកទាំងបី។

ឈ្មោះ [redacted] ថាវី ជាសាក្សី បានឆ្លើយថា រឿងហេតុថាឈ្មោះ គ ឈ្មោះ គោយ និងឈ្មោះ ជា ចាប់រំលោភសេពសន្ថវៈឈ្មោះ [redacted] សីម៉ា កាលពីយប់ម៉ោង៨ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២ នោះខ្លួនពុំបានឃើញផ្ទាល់ភ្នែកនោះទេ និងពុំបាននិយាយប្រាប់ឈ្មោះ [redacted] សីម៉ា និងឈ្មោះ [redacted] ណារី នោះដែរ គឺខ្លួននិយាយប្រាប់អ្នកទាំងពីរមែនតែពេលល្ងាចខ្លួនឃើញឈ្មោះ [redacted] សីម៉ា ហូបស្រានៅផ្ទះរបស់ឈ្មោះ គោយ ជាមួយឈ្មោះ គ និងឈ្មោះ ជា ហើយឈ្មោះ ជា បានទិញស្រាខ្លួន១យួរ ទៀតផង ដល់ម៉ោងជាង៦ ខ្លួននាំកូនដេក ហើយខ្លួនក៏ពុំដឹងថារឿងអ្វីនៅផ្ទះឈ្មោះ គោយ ទេ។

ឈ្មោះ [redacted] ស្រេង ជាសាក្សី បានឆ្លើយថា នៅម៉ោង៣រសៀល ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២២ មានឈ្មោះ [redacted] ណារី នាំប្អូនស្រីឈ្មោះ [redacted] សីម៉ា មកផ្ទះខ្លួន និងប្រាប់ខ្លួនថា កាលពីម៉ោង៨ យប់ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ មានឈ្មោះ គោយ ឈ្មោះ គ និងឈ្មោះ ជា ចាប់រំលោភឈ្មោះ [redacted] សីម៉ា នៅផ្ទះឈ្មោះ គ ពេលផឹកស្រាស្រវឹងឱ្យខ្លួនជួយដោះស្រាយ ដល់ម៉ោង ៧ ព្រឹកថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ខ្លួនហៅបានតែឈ្មោះ គ និងឈ្មោះជា មកផ្ទះខ្លួនពេលខ្លួនសួរអ្នកទាំងពីរឆ្លើយបដិសេធ បានបន្តិចនគរបាលប៉ុស្តិ៍ទៅដល់ ឱ្យខ្លួនជូនអ្នកទាំងពីរទៅផ្ទះឈ្មោះ គ ជួបឈ្មោះ គោយ នៅទីនោះហើយនគរបាលក៏នាំអ្នកទាំងបីនាក់ទៅប៉ុស្តិ៍។

ឈ្មោះ [redacted] សារីម ជាសាក្សី បានឆ្លើយថា ខ្លួនដឹងពីមេភូមិកាលពីល្ងាចថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២២ ថាប្តីខ្លួនឈ្មោះ ជា ឈ្មោះ គ និងឈ្មោះ គោយ ចាប់រំលោភឈ្មោះ [redacted] សីម៉ា កាលពីម៉ោង៨ យប់ ថ្ងៃទី០៥ ខែមីនាឆ្នាំ២០២២ នៅផ្ទះឈ្មោះ គ បន្ទាប់មកខ្លួនបានសួរប្តីខ្លួនឈ្មោះ គ និងឈ្មោះ គោយ អ្នកទាំងបីនាក់ប្រាប់ថាគ្រាន់តែបានផឹកស្រាជាមួយឈ្មោះ សំ សីម៉ា ពីល្ងាចថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ នោះ តែពុំបានចាប់រំលោភឈ្មោះ [redacted] សីម៉ា ទេ ។

ឈ្មោះ [redacted] ណារី ជាសាក្សី បានឆ្លើយថា រឿងគេចាប់រំលោភប្អូនស្រីខ្លួនឈ្មោះ [redacted] សីម៉ា កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ នៅវេលាម៉ោងប្រហែល៨យប់ គឺខ្លួនពុំបានឃើញផ្ទាល់ទេ គឺខ្លួនបានដឹងពេលប្អូនស្រីខ្លួនប្រាប់ពេលព្រឹកថ្ងៃទី

០៦ ខែមីនា ឆ្នាំ២០២២ គឺពេលនោះប្អូនខ្លួនយំសុំលុយ ខ្លួនទិញថ្នាំអូខេកុំឱ្យមានកូន ខ្លួនសួរវាប្រាប់ ថា កាលពីល្ងាចថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២២ ឈ្មោះ គោយ ឈ្មោះ គ និងឈ្មោះ ជា ហៅវាផឹកនៅផ្ទះរបស់ឈ្មោះ គ ដល់ម៉ោង៨យប់ អ្នកទាំង៣នាក់ចាប់រំលោភវា ខ្លួនក៏ទៅសួរអ្នកក្បែរនោះឈ្មោះ គោ ថារី គឺខ្លួនទិញទឹកគ្រឡាច ហើយខ្លួនសួរថាមានដឹងរឿងអីយប់មិញនៅផ្ទះឈ្មោះ គ ទេ ឈ្មោះ នេះថា ឃើញអ្នកទាំង៣នាក់ ចាប់រំលោភប្អូនស្រីខ្លួន និងហាមខ្លួនមិនឱ្យមាត់ និងថាមានតែខ្លួនទេបានជួយរកយុត្តិធម៌ឱ្យប្អូន ទើបខ្លួននាំប្អូនស្រីទៅប្តឹងប្រធានភូមិនិងនគរបាលរហូតចាប់ខ្លួនអ្នកទាំងបី។

តំណាងអយ្យការ បានសន្និដ្ឋានថាឆ្លងតាមសវនាការ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឃើញថាជនជាប់ចោទឈ្មោះ [redacted] ជា , ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ស៊ាន ពិតជាបានប្រព្រឹត្តដូចបទចោទប្រកាន់មែន តំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ: ១១៩អ.យ.គ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ទុកជាបានការពេញទាំងមូល ស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា:ឆ្លងតាមអង្គសវនាការនេះ ជនរងគ្រោះឆ្លើយហាក់បីដូចជាមានភាពស្រពិចស្រពិល កូនក្តីខ្លួនបានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្ត គ្រាន់តែបានចូលរួមផឹកស៊ីតែប៉ុណ្ណោះ ពុំមានភស្តុតាងណាមួយបញ្ជាក់ថា កូនក្តីខ្លួនបានប្រព្រឹត្តនោះទេ គឺស្ថិតនៅក្នុងវិមតិសង្ស័យ តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដូច្នេះខ្លួនសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់ និងដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពវិញ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
-ក្រោយពីបានពិនិត្យភស្តុតាងនានា
-ក្រោយពីបានពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តស្វាយរៀង
## យល់ឃើញថា

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ នៅចំណុចភូមិអង្គសជី ឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង មានករណី **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស** មួយបង្កឡើងដោយជនសង្ស័យចំនួន០៣នាក់ ១.ឈ្មោះ [redacted] ជា ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ២.ឈ្មោះ [redacted] សាមឿន ហៅ គ ភេទប្រុស អាយុ៤៦ឆ្នាំ ជនជាតិខ្មែរ ៣.ឈ្មោះ [redacted] ស៊ាន ហៅ គោយ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ បានរួមគ្នាធ្វើសកម្មភាពចាប់រំលោភជនរងគ្រោះឈ្មោះ [redacted] សីម៉ា ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ បានសម្រេចក្រោយពេលកើតហេតុជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានចុះដល់កន្លែងកើតហេតុធ្វើការស្រាវជ្រាវ រហូតដល់ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ទើបធ្វើការឃាត់ខ្លួនជនសង្ស័យទាំង ៣ នាក់ ខាងលើមកធ្វើការសាកសួរ រួចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមនីតិវិធីតែម្តង។

តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ជា ជាជនជាប់ចោទ បានឆ្លើយថា ខ្លួនពុំបានចូលរួមប្រព្រឹត្តបទល្មើសរំលោភនារីឈ្មោះ [redacted] សីម៉ា កាលពីម៉ោង៨ យប់ នាថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ នោះទេ តែខ្លួនបានចូលផឹកស៊ីជាមួយឈ្មោះ [redacted] សីម៉ា នៅផ្ទះឈ្មោះ [redacted] សាមឿន ហៅ គ ចាប់ពីម៉ោង៦ ល្ងាច ដល់ម៉ោង ៨ យប់ នាង សីម៉ា និងអ្នកផ្សេងទៀតចេញទៅផ្ទះ ឯខ្លួននៅបង្ហើយស្រាជាមួយឈ្មោះ មឿន រួចចេញទៅផ្ទះម្នាក់ឯង។ លុះព្រឹកឡើងឮថាខ្លួនចាប់រំលោភគេទៅវិញ។ សំណូមពរតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។

តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សាមឿន បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចបទចោទប្រកាន់នោះទេ តែល្ងាចនោះនៅផ្ទះខ្លួនមានហូបចុក រួមទាំងមាននាង សីម៉ា ផងដែរដល់ម៉ោង៧យប់ ឈ្មោះ [redacted] ស៊ាន ទៅផ្ទះមុនប្រហែល



Scanned with CamScanner

៥នាទី នាងសីម៉ា ទៅតាមក្រោយឯខ្លួន និងបងជា នៅបង្អើយស្រា ទល់បងជាទៅផ្ទះ ឯខ្លួនក៏ទៅដេក ដល់ព្រឹកថាពួកខ្លួនរំលោភ នាង សីម៉ា ទៅវិញ។ សំណូមពរតុលាការរកយុត្តិធម៌ឲ្យខ្លួនផង។

តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ស៊ាន បានឆ្លើយថា ខ្លួនពុំបានប្រព្រឹត្តដូចបទចោទប្រកាន់ ប៉ុន្តែកាលពីល្ងាចថ្ងៃនោះបានផឹកស៊ីនៅផ្ទះឈ្មោះ សាមឿន ជាមួយនាងសីម៉ា ពិតមែន។ ដល់ម៉ោង៨ យប់ ខ្លួនចេញទៅផ្ទះដោយជិះកង់ ចំណែកនាងសីម៉ា ម្ចាស់ផ្ទះសាមឿន និងឈ្មោះ ជា នៅហូបបន្ត ដល់ព្រឹកឮថា ពួកខ្លួនចាប់រំលោភនាងសីម៉ា ទៅវិញ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ខ្លួនត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ សំណូមពរតុលាការរកយុត្តិធម៌ឲ្យខ្លួនផង។

តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីម៉ា បានឆ្លើយថា ខ្លួននៅតែប្តឹងឈ្មោះ [redacted] ស៊ាន ហៅ គោយ ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ជា ដែលអ្នកទាំងបីនាក់នេះបានចាប់រំលោភសេពសន្ថវៈលើខ្លួន កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល៨យប់ ដដែល ដោយកាលពីល្ងាចថ្ងៃខ្លួនមកពីធ្វើក្រចកឲ្យអ្នកភូមិ ជិះកង់ជិតដល់ផ្ទះរបស់ឈ្មោះ សាមឿន ហៅ គ ស្រាប់តែឈ្មោះ [redacted] ស៊ាន ហៅ គោយ ឃាត់ឲ្យខ្លួនចូលផឹកជាមួយពួកគាត់សិន។ ពេលខ្លួនចូលទៅផឹកមានគ្នាចំនួន០៣នាក់ គឺម្ចាស់ផ្ទះឈ្មោះ សាមឿន ហៅ គ ឈ្មោះ គោយ និងឈ្មោះ ជា ឯម្ចាស់ផ្ទះស្រីនៅភ្នំពេញ។ ពេលខ្លួនផឹកបានបន្តិចខ្លួនទៅផ្ទះវិញ តែឈ្មោះ គោយ ចាប់ឃាត់ឲ្យនៅផឹកទៀត រហូតខ្លួនស្រវឹង ខ្លួនក៏បរកង់ចេញ ក៏ចាប់យកកង់ខ្លួនលាក់បាត់ ខ្លួនសួររកត្រូវឈ្មោះ គោយ ចាប់អោបថើបនៅក្នុងភូមិផ្ទះ សាមឿន ខ្លួនរើបម្រាស់ក៏ឈ្មោះ សាមឿន និងឈ្មោះ ជាមកជួយចាប់ខ្លួនរើលែងបាន ត្រូវឈ្មោះ គោយ រំលោភ និងមានម្រាមដៃរុកចូលច្រមុះខ្លួនទាំងពីរ បណ្តាលឲ្យខ្លួនសន្លប់លែងដឹងខ្លួន គឺច្បាស់ជាឈ្មោះ សាមឿន និងឈ្មោះ ជា រំលោភខ្លួនដែរ។ ពេលខ្លួនដឹងខ្លួន ដើរទៅផ្ទះដេកសន្លប់ទៀតរហូតទាល់ភ្លឺទើបដឹងខ្លួន ខ្លួនប្រាណប្រឡាក់ដី ពេលនោះខ្លួនជិះកង់ដែលខ្លួនយកបានទៅយកស្បែកជើង តែពុំឃើញស្រាប់តែបងស្រីឈ្មោះ [redacted] ថាវី ប្រាប់ខ្លួនថាគាត់ឃើញអ្នកទាំងបីចាប់រំលោភខ្លួន និងសួរថារឿងណឹងមិចហើយ ខ្លួនក៏ទៅប្រាប់បងស្រីឈ្មោះ [redacted] ណារី ថាអ្នកទាំងបីនាក់ ចាប់រំលោភខ្លួន កាលពីយប់មិញ ខ្លួនទៅប្តឹងប្រធានភូមិ រហូតសមត្ថកិច្ចហៅ ខ្លួនទៅចង្អុលមុខ។ ក្នុងរឿងនេះខ្លួនប្តឹងសុំទាមទារជំងឺចិត្តចំនួន១៥ ០០០ដុល្លារអាមេរិក។

តាមចម្លើយសាក្សីឈ្មោះ [redacted] ចំពូ បានឆ្លើយថា រឿងហេតុកូនស្រីខ្លួនឈ្មោះ [redacted] សីម៉ា ត្រូវគេចាប់រំលោភកាលពីយប់ថ្ងៃទី០៥ ខែមីនាឆ្នាំ២០២២ គឺខ្លួនពុំបានឃើញផ្ទាល់ភ្នែកទេ ដោយពេលមុនកើតហេតុកូនខ្លួនជាស្រីមេម៉ាយ រស់នៅជាមួយខ្លួន និងកូនវាម្នាក់ដែរ ហើយចេះធ្វើក្រចកដៃជើង ឲ្យគេនៅថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃសម្រាករបស់កម្មករ គឺទៅធ្វើល្ងាចទើបជិះកង់មកវិញ តែថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ ខ្លួនពុំឃើញកូនស្រីខ្លួនត្រឡប់មកផ្ទះវិញ ខ្លួនក៏អង្គុយចាំរហូតដល់ម៉ោង ៨ យប់ ទើបឃើញបរកង់មក ខ្លួនសុទ្ធតែដី តែខ្លួនសួរ វាពុំមាត់ចេះតែយប់ និងទៅដេកថ្ងូរ ខ្លួនមិនស្រួលខ្លួនក៏ទៅដេកដែរ។ រហូតព្រឹកឡើងទើបវា ប្រាប់ខ្លួន និងបងស្រីវាថា យប់មិញឈ្មោះ គោយ ឈ្មោះ គ និងឈ្មោះ ជា ចាប់រំលោភវា ហើយវា និងបងវា ទៅប្តឹងសមត្ថកិច្ចរហូតចាប់បានអ្នកទាំងបី។

តាមចម្លើយសាក្សីឈ្មោះ [redacted] ថាវី បានឆ្លើយថា រឿងហេតុថាឈ្មោះ គ ឈ្មោះ គោយ និងឈ្មោះ ជា ចាប់រំលោភសេពសន្ថវៈឈ្មោះ [redacted] សីម៉ា កាលពីយប់ម៉ោង៨ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២ នោះខ្លួនពុំបានឃើញផ្ទាល់ភ្នែកនោះទេ និងពុំបាននិយាយប្រាប់ឈ្មោះ [redacted] សីម៉ា និងឈ្មោះ [redacted] ណារី នោះដែរ គឺខ្លួននិយាយប្រាប់អ្នកទាំងពីរមែនតែពេលល្ងាចខ្លួនឃើញឈ្មោះ [redacted] សីម៉ា ហូបស្រានៅផ្ទះរបស់ឈ្មោះ គោយ ជាមួយឈ្មោះ គ និងឈ្មោះ ជា ហើយឈ្មោះ ជា បានទិញស្រាខ្លួន១យួរ ទៀតផង ដល់ម៉ោងជាង៦ ខ្លួននាំកូនដេក ហើយខ្លួនក៏ពុំដឹងថារឿងអ្វីនៅផ្ទះឈ្មោះ គោយ ទេ។

តាមចម្លើយសាក្សីឈ្មោះ [redacted] ស្រេង បានឆ្លើយថា នៅម៉ោង៣រសៀល ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២២ មានឈ្មោះ [redacted] ណារី នាំប្អូនស្រីឈ្មោះ [redacted] សីម៉ា មកផ្ទះខ្លួន និងប្រាប់ខ្លួនថា កាលពីម៉ោង៨ យប់ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ មានឈ្មោះ គោយ ឈ្មោះ គ និងឈ្មោះ ជា ចាប់រំលោភឈ្មោះ [redacted] សីម៉ា នៅផ្ទះឈ្មោះ គ ពេលផឹកស្រាស្រវឹងឲ្យខ្លួនជួយដោះស្រាយ ដល់ម៉ោង ៧ ព្រឹកថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ខ្លួនហៅបានតែឈ្មោះ គ និងឈ្មោះជា មកផ្ទះខ្លួនពេលខ្លួនសួរអ្នកទាំងពីរ ឆ្លើយបដិសេធ បានបន្តិចនគរបាលប៉ុស្តិ៍ទៅដល់ ឲ្យខ្លួនជូនអ្នកទាំងពីរទៅផ្ទះឈ្មោះ គ ជួបឈ្មោះ គោយ នៅទីនោះហើយនគរបាលក៏នាំអ្នកទាំងបីនាក់ទៅប៉ុស្តិ៍។



Scanned with CamScanner

តាមចម្លើយសាក្សីឈ្មោះ [redacted] សារីម បានឆ្លើយថា ខ្លួនដឹងពីមេភូមិកាលពីល្ងាចថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២២ ថាប្តីខ្លួនឈ្មោះ ជា ឈ្មោះ គ និងឈ្មោះ គោយ ចាប់រំលោភឈ្មោះ [redacted] សីម៉ា កាលពីម៉ោង៨ យប់ ថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០២២ នៅផ្ទះឈ្មោះ គ បន្ទាប់មកខ្លួនបានសួរប្តីខ្លួនឈ្មោះ គ និងឈ្មោះ គោយ អ្នកទាំងបីនាក់ប្រាប់ថាគ្រាន់តែបានផឹកស្រាជាមួយឈ្មោះ [redacted] សីម៉ា ពីល្ងាចថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ នោះ តែពុំបានចាប់រំលោភឈ្មោះ [redacted] សីម៉ា ទេ ។

តាមចម្លើយសាក្សីឈ្មោះ [redacted] ណារី បានឆ្លើយថា រឿងគេចាប់រំលោភប្អូនស្រីខ្លួនឈ្មោះ [redacted] សីម៉ា កាលពីថ្ងៃទី ០៥ ខែមីនាឆ្នាំ២០២២ នៅវេលាម៉ោងប្រហែល៨យប់ គឺខ្លួនពុំបានឃើញផ្ទាល់ទេ គឺខ្លួនបានដឹងពេលប្អូនស្រីខ្លួនប្រាប់ពេលព្រឹកថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២២ គឺពេលនោះប្អូនខ្លួនយំសុំលុយ ខ្លួនទិញថ្នាំអូខេកុំឲ្យមានកូន ខ្លួនសួរវាប្រាប់ ថា កាលពីល្ងាចថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ ឈ្មោះ គោយ ឈ្មោះ គ និងឈ្មោះ ជា ហៅវាផឹកនៅផ្ទះរបស់ឈ្មោះ គ ដល់ម៉ោង៨ យប់ អ្នកទាំង៣នាក់ចាប់រំលោភវា ខ្លួនក៏ទៅសួរអ្នកក្បែរនោះឈ្មោះ តោ ថារី គឺខ្លួនទិញទឹកគ្រឡាច ហើយខ្លួនសួរថាមានដឹងរឿងយប់មិញនៅផ្ទះឈ្មោះ គ ទេ គឺឈ្មោះ នេះថា ឃើញអ្នកទាំង៣នាក់ ចាប់រំលោភប្អូនស្រីខ្លួន និងហាមខ្លួនមិនឲ្យមាត់ និងថាមានតែខ្លួនទេបានជួយរកយុត្តិធម៌ឲ្យប្អូន ទើបខ្លួននាំប្អូនស្រីទៅប្តឹងប្រធានភូមិនិងនគរបាលរហូតចាប់ខ្លួនអ្នកទាំងបី។

ជនជាប់ចោទទាំងបីនាក់បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច និងចំពោះមុខតំណាងអយ្យការថា ខ្លួនបានរំលោភសេពសន្ថវៈទៅលើឈ្មោះ [redacted] សីម៉ា តែនៅចំពោះមុខចៅក្រមស៊ើបសួរ និងពេលសវនាការនេះ បានឆ្លើយបដិសេធ នៅពេលផឹកស៊ីអ្នកទាំងបីនាក់បានយកដៃបេះបោច និងថើបទៅលើជនរងគ្រោះ គប្បីតុលាការជឿថាជនជាប់ចោទ ពិតជាបានប្រព្រឹត្តដូចបទចោទប្រកាន់ពិតមែន។

ផ្អែកតាមចម្លើយជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី មានលក្ខណៈស៊ីសង្វាក់ទៅនឹងអង្គហេតុអាចធ្វើឲ្យតុលាការជឿថា: ជនជាប់ចោទឈ្មោះ [redacted] ជា , ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ស៊ាន ពិតជាបានប្រព្រឹត្តដូចបទល្មើសមែន គប្បីតុលាការផ្តន្ទាទោសតាមច្បាប់។

តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ជា ,ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ស៊ាន បានឆ្លើយនៅពេលសវនាការថា ខ្លួនពុំបានប្រព្រឹត្តដូចបទចោទប្រកាន់នោះទេ ចំពោះចម្លើយខ្លួន ដែលឆ្លើយសារភាពនៅដំណាក់កាលសមត្ថកិច្ចនោះខ្លួនបានឆ្លើយថា ខ្លួនទាំងបីនាក់ពិតជាបានរំលោភលើជនរងគ្រោះឈ្មោះ [redacted] សីម៉ា នោះ គឺពុំពិតនោះទេ ដោយសារសមត្ថកិច្ចបានប្រើអំពើហិង្សាមកលើខ្លួន ទើបខ្លួនឆ្លើយបែបនេះ។

ឈ្មោះ [redacted] សីម៉ា ជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងសុំទាមទារសំណងពីជនជាប់ចោទទាំងបីនាក់ចំនួន១៥០០០ ដុល្លារអាមេរិក គប្បីតុលាការពិនិត្យ និងពិចារណាសម្រេចតាមច្បាប់។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទ៖ឈ្មោះ [redacted] ជា ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ស៊ាន ពីបទ: *រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងទៅនឹងជនល្មើស* ប្រព្រឹត្តនៅភូមិអង្គាសជី ឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៤០ កថាខណ្ឌទី១ ចំណុចទី៥ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទជាមនុស្សមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្ត

អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅក្នុងសង្គម ដែលគប្បីត្រូវផ្តន្ទាទោសតាមច្បាប់។

តំណាងអយ្យការនៅរក្សាបទៈចោទប្រកាន់ដដែលនិងសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## <u>ហេតុដូច្នេះសាលាដំបូងខេត្តស្វាយរៀង</u>
## <u>វិនិច្ឆ័យសេចក្តីដូចតទៅ</u>

១.ផ្តន្ទាទោសលើជនជាប់ចោទ៖

ក.ឈ្មោះ [redacted] ជា ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ (មានសាវតាជាតិដូចខាងលើ)

ខ.ឈ្មោះ [redacted] សាមឿន ភេទប្រុស អាយុ៤៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ (មានសាវតាជាតិដូចខាងលើ)



Scanned with CamScanner

គ.ឈ្មោះ [redacted] ស៊ាន ហៅ គោយ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ (មានសាវតាពិជាតិដូច ខាងលើ) អ្នកទាំងបីនាក់ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់: ៨ (ប្រាំបីឆ្នាំ) គិតពីថ្ងៃឃុំខ្លួន។

ពីបទៈ *រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងទៅនឹងជនល្មើស* ប្រព្រឹត្ត នៅភូមិអង្គាសជី ឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែល មានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៤០ កថាខណ្ឌទី១ ចំណុចទី៥ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឲ្យឈ្មោះ [redacted] ជា ,ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ស៊ាន រួមគ្នាសងសំណងថ្លៃខូចខាត និង សំណងជំងឺចិត្តជាប្រាក់ចំនួន:២០ ០០០ ០០០(ម្ភៃលានរៀល) ឲ្យទៅឈ្មោះ [redacted] ស៊ីម៉ា ជាដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពី ពេលសាលក្រមចូលជាស្ថាពរ។ សំណូមពរលើសពីនេះលើកចោល។

៣.សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជា , ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ស៊ាន និងដើមបណ្តឹងរដ្ឋ ប្បវេណីឈ្មោះ [redacted] ស៊ីម៉ា។

"បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់"

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

........................................................................................................................................................................

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ព្រហស្បតិ៍១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ស្វាយរៀង, ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]



Scanned with CamScanner